ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១០ សរណន

# សារាចរណែនាំ
## ស្តីពីការពាក់គ្រឿងឥស្សរិយយស

កន្លងមករាជរដ្ឋាភិបាល បានពិនិត្យឃើញថា មានមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ សប្បុរសជន ក្នុងប្រទេស និង ក្រៅប្រទេស ព្រមទាំងជនបរទេសជាច្រើន បានចូលរួមក្នុងកិច្ចការពារជាតិមាតុភូមិ និង អភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ហើយត្រូវបានព្រះមហាក្សត្រ និង រាជរដ្ឋាភិបាល បានលើកទឹកចិត្តផ្តល់គ្រឿងឥស្សរិយយស ទៅតាមទំហំស្នាដៃដែលសំរេចបាន និង មានរៀបចំពិធីបំពាក់ជាបន្តបន្ទាប់ ។

ដើម្បីអោយមានការឯកភាពគ្នា ក្នុងការពាក់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាល សូមធ្វើការណែនាំដល់គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង អំពីរបៀបពាក់គ្រឿងឥស្សរិយយស ដូចខាងក្រោមនេះ :-

១-រាល់គ្រឿងឥស្សរិយយសគ្រប់ប្រភេទ លុះត្រាតែមានចេញព្រះរាជក្រឹត្យ អនុក្រឹត្យ ហើយទើបមានសិទ្ធិយកទៅបំពាក់ជូនដល់អ្នកមានស្នាដៃទាំងនោះបាន ។ ក្នុងការបំពាក់នេះ ត្រូវរៀបចំពិធីអោយបានត្រឹមត្រូវ មានសភាពអធិកអធម ដូចជាក្នុងពិធីសម្ពោធ មិទ្ទីញ សិក្ខាសាលា ជាដើម ។ ក្នុងករណីពិសេសបន្ទាន់ និង ចាំបាច់ និងមានការអនុញ្ញាតពីរាជរដ្ឋាភិបាល អាចរៀបចំពិធីបំពាក់ជាមុន នូវគ្រឿងឥស្សរិយយស ដែលចេញដោយអនុក្រឹត្យ រួចនឹងធ្វើសំណុំបែបបទជាក្រោយ ។

២-គ្រឿងឥស្សរិយយសប្រភេទណាក៏ដោយ ក្រោយពីព្រះមហាក្សត្រ ចេញព្រះរាជក្រឹត្យ និង រាជរដ្ឋាភិបាល ចេញអនុក្រឹត្យរួចហើយ អ្នកដែលមានសិទ្ធិបំពាក់នោះ គឺជាមន្ត្រីជាន់ខ្ពស់ ដែលព្រះមហាក្សត្រ ឬ រាជរដ្ឋាភិបាល ទ្រង់ព្រះរាជានុញ្ញាត និង អនុញ្ញាតអោយទៅជាតំណាង ទើបមានសិទ្ធិបំពាក់បាន ។

៣-របៀបបំពាក់គ្រឿងឥស្សរិយយស ត្រូវពាក់ទៅតាមឋានានុក្រម ពីធំទៅតូច និង ពីស្តាំទៅឆ្វេងអ្នកដែលពាក់ ដូចខាងក្រោមនេះ :-

-មេដាយជាតូបការ គឺជាមេដាយខ្ពស់បំផុតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការបំពាក់មេដាយ នេះ គឺពាក់របៀបដូចជាពាក់ខ្សែកដែលមានបន្តោង ។

-មេដាយដែលមានថ្នាក់ មហាសេរីវឌ្ឍន៍ ថ្នាក់ មហាសេនា ត្រូវពាក់ជាមួយសំពត់រុយបង់ពីលើស្មាខាងស្តាំ បញ្ឆៀងមកចង្កេះខាងឆ្វេង ។ ប៉ុន្តែក្នុងករណីមិនពាក់ជាមួយសំពត់រុយបង់ទេ គឺត្រូវពាក់នៅដើមទ្រូង ក្រោមហោប៉ៅអាវខាងឆ្វេង ។

-មេដាយគ្រប់ប្រភេទ ដែលមានថ្នាក់ធិបឌិន្ទ ត្រូវពាក់ព្យួរនឹងក ដែលចងភ្ជាប់ជាមួយសំពត់រុយបង់ ហើយតួមេដាយត្រូវអោយធ្លាក់មកចំកណ្តាលដើមទ្រូង ។

-មេដាយដែលមានតែមួយថ្នាក់ និង មេដាយថ្នាក់ សេនា អស្សឫទ្ធិ ហើយនិង មាស ប្រាក់ សំរិទ្ធ ត្រូវពាក់នៅលើគំរបហោប៉ៅអាវខាងឆ្វេង ស្មើនឹងឡេវអាវទី២ ដោយតម្រៀបគ្នាពីស្តាំទៅឆ្វេង ពីថ្នាក់ខ្ពស់ ទៅថ្នាក់ទាប ។ ក្នុងករណីបានទទួលមេដាយច្រើនប្រភេទ ត្រូវពាក់មេដាយដែលចេញដោយព្រះរាជក្រឹត្យលើ ហើយថ្នាក់អនុក្រឹត្យ នៅក្រោមបន្ទាប់ និង តាមលំដាប់ថ្នាក់មេដាយ ។

-រាល់សញ្ញាសំគាល់សក្តិ សញ្ញាសំគាល់ក្រសួង ស្ថាប័ន អង្គភាពនិមួយៗ ត្រូវពាក់នៅលើគំរបហោប៉ៅអាវខាងស្តាំ មិនគប្បីពាក់នៅដើមទ្រូងខាងឆ្វេងទេ ព្រោះខាងឆ្វេងទុកសំរាប់បំពាក់គ្រឿងឥស្សរិយយស ប៉ុណ្ណោះ ។

៤-តួមេដាយគ្រប់ប្រភេទ ពាក់បានតែក្នុងពិធីបុណ្យជាតិ និង បុណ្យប្រពៃណីជាតិធំៗ ដូចជាបុណ្យឯករាជ្យជាតិ បុណ្យអុំទូក ជាដើម ពាក់តែតួមេដាយ មិនពាក់បារ៉ែតទេ គឺពាក់ជាមួយឯកសណ្ឋានធំ ក្រៅពីនេះ ដូចជាថ្ងៃធ្វើការងារ ឬ ក្នុងពិធីប្រជុំធំៗ អាចពាក់បានតែនៅលើឯកសណ្ឋានការងារ ហើយត្រូវពាក់តែបារ៉ែតទេ ដោយគ្មានតួមេដាយ ។

រាជរដ្ឋាភិបាល សង្ឃឹមជឿជាក់ថា គ្រប់ក្រសួង ស្ថាប័ន គ្រប់ជាន់ថ្នាក់ នឹងចាត់ចែងអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះ ប្រកបដោយស្មារតីយកចិត្តទុកដាក់ សំដៅរក្សាអោយបាននូវតម្លៃនៃគ្រឿងឥស្សរិយយសរបស់ជាតិ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច និង ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការដ្ឋាន
-គ្រប់ខេត្ត ក្រុង
-រាជកិច្ច
-កាលប្បវត្តិ-ឯកសារ